ឆ្នាំ2026ខែ4
សមាគមGTS

# ជូនទៅកាន់កម្មសិក្សាការីទាំងអស់គ្នា

ពេលនេះគឺជារដូវរំហើយ ជាពេលដែលពោរពេញទៅដោយផ្ការីកនៅប្រទេសជប៉ុន ។
តើអ្នកទាំងអស់គ្នានៅប្រទេសជប៉ុនដោយសុខសប្បាយជាទេ?
 រដូវកាលនេះក៏ជារដូវកាលដែលមានការផ្លាស់ប្តូរសីតុណ្ហភាពខ្លាំង។សីតុណ្ហភាពទាបនៅពេលព្រឹកនិងពេលល្ងាច ហើយអំឡុងពេលថ្ងៃត្រង់សីតុណ្ហភាពអាចកើនឡើងដូចរដូវក្តៅ។
អាស្រ័យទៅតាមអាកាសធាតុ ពេលថ្ងៃត្រង់ខ្លះក៏អាចនឹងត្រជាក់ផងដែរ។
សូមរក្សាសុខភាព ដោយកុំឲ្យមានជំងឺឈឺស្កាត់។
 ជិតដល់ថ្ងៃឈប់សម្រាក់មួយសប្តាហ៍ហើយ
សូមអ្នកទាំងអស់គ្នាប្រកាន់នូវអកប្បកិរិយាសមរម្យ
និងប្រកាន់នូវឲ្យទំលាប់ល្អក្នុងការរស់នៅប្រចាំថ្ងៃ។
ទោះជានៅក្នុងកាលៈទេសណាក៏ដោយតើអ្នកអាចឆ្លើយដោយមានជំនឿចិត្តបានទេ?
ថាអ្នកគឺជាសិស្សច្បងគំរូបានទេ?
 សូមរស់នៅប្រទេសជប៉ុនដោយមានមោទនភាពហើយគិតថាខ្លួនយើងម្នាក់ៗតំណាងឲ្យប្រទេសកម្ពុជា។ប្រសិនបើអ្នកបំពានច្បាប់ប្រទេសជប៉ុន
ជនជាតិជប៉ុននឹងមានគំនិតគិតថាមិនមែនត្រឹមតែអ្នកជាមនុស្សមិនល្អនោះទេ
ថែមទាំងគិតថាជនជាតិកម្ពុជាទាំងអស់គឺជាមនុស្សមិនល្អ។
 សកម្មភាពមិនល្អរបស់មនុស្សម្នាក់អាចនាំឲ្យ
គេគិតថាជនជាតិរបស់អ្នកមិនល្អទាំងអស់បាន។
សូមរស់នៅប្រទេសជប៉ុនដោយមានទំនួរខុសត្រូវថាខ្លួនជាអ្នកតំណាងដោយប្រទេសម្នាក់។
កុំក្បត់អ្នកដែលកំពុងថែរក្សាអ្នក។ ប្រសិនបើអ្នកបាត់បងការជឿជាក់តែម្តង
អ្នកនឹងមិនអាចរកវាមកវិញបានទេ។ ដូចនេះសូមប្រុងប្រយ័ត្នរាល់សកម្មភាពរបស់អ្នក។

## ចំណាំ

### 1.អំពីជំងឺ

ការការពារជំងឺផ្តាសាយ ផ្តាសាយធំប្រភេទថ្មី

- ពេលត្រលប់មកពីខាងក្រៅ, មុនចំអិនអាហារដាច់ខាតត្រូវលាងដៃនិងខ្ពុរមាត់។
- ត្រូវរស់នៅដោយត្រឹមត្រូវទៅតាមច្បាប់(កុំនៅដល់យប់ជ្រៅពេក)
- ត្រូវយកចិត្តទុកដាក់ទៅលើរបបអាហារញ៉ាំដែលផ្តល់ជីវជាតិគ្រប់គ្រាន់។

### 2. អំពីគ្រោះថ្នាក់ចរាចរណ៍

 ត្រូវគោរពច្បាប់ចរាចរណ៍ប្រទេសជប៉ុនអោយបានខ្ជាប់ខ្ជួន
ដើម្បីកុំអោយជួបគ្រោះថ្នាក់ចរាចរណ៍។
ត្រូវតែមានទូរស័ព្ទដៃ,កាតស្នាក់នៅនិងកាតទំនាក់ទំនង, ជាមួយជានិច្ច
ប្រសិនបើមានគ្រោះថ្នាក់កើតឡើងសូមទំនាក់ទំនងទៅសមាគម។
 នៅពេលកើតស្ថានភាពមិនបានគ្រោងទុកត្រូវរក្សាអារម្មណ៍ ហើយសូមទំនាក់ទំនងទៅអ្នកស្នាក់នៅជាមួយ និង សមាគមលើសពីនេះត្រូវគោរពច្បាប់ចរាចរពេលជិះកង់។

គោរពច្បាប់ចរាចរណ៍ គោរពជីវិតខ្លួនឯង។

**3. អំពីការងារក្រៅម៉ោង**

ហាងដាច់ខាតមិនឲ្យកម្មសិក្សាការីធ្វើការងារក្រៅម៉ោងនិងការងារធ្វើតាមផ្ទះបាននោះទេ!
ការទទួលយកប្រាក់ឈ្នួលនៅតាមគ្រឹះស្ថាននិងហាងផ្សេងៗគឺជាសកម្មភាពខុសច្បាប់ ហើយនឹងបណ្ដាលឲ្យក្រុមហ៊ុននិងសមាគមរបស់អ្នកត្រូវទទួលទោសផងដែល!លើសពីនេះនៅទៀតវាជាសកម្មភាពមួយខុសពីការហ្វឹកហ្វឺនជំនាញជាក់ស្ដែង ហើយអ្នកនឹងត្រូវបញ្ជូនវិលត្រឡប់ទៅផ្ទះវិញ។

**4. អំពីការរញ្ជួយដី**

ប្រទេសជប៉ុនត្រូវបានគេដឹងថាជាប្រទេសដែលមានការរញ្ជួយដីជាច្រើន។ ប្រសិនបើមានការរញ្ជួយដីកើតមានឡើងតើអ្នកគួរធ្វើអ្វី? តើអ្នកទាំងអស់គ្នាដឹងដែរឬទេ? បន្ទាប់ពីអ្នកមើលសៀវភៅ（https://www.bousai.go.jp/kyoiku/gensai/index.html) ស្ដីពីសៀវភៅណែនាំអំពីការការពារគ្រោះមហន្តរាយរបស់ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយ និងទីភ្នាក់ងារអគ្គិភ័យ អ្នកនឹងទទួលបានទទួលចំណេះដ៏ល្អ។

**5.ផ្សេងៗ**

ដាច់ខាត់ត្រូវគោរពច្បាប់ក្រុមហ៊ុន ច្បាប់នៅកន្លែងស្នាក់នៅ និងច្បាប់របស់ប្រទេសជប៉ុន។ឧក្រិដ្ឋជនត្រូវបានដាក់ទោសដោយមិនគិតពីជនជាតិជប៉ុន ឬជនបរទេសឡើយ។ ប្រសិនបើអ្នកធ្លាប់ជាប់បទព្រហ្មទណ្ឌហើយ អ្នកនឹងមិនអាចលុបប្រវត្តិនោះបានទេ។
・ហាមឃាត់ការស្នាក់ខាងក្រៅដោយមិនមានការអនុញ្ញាត។ ចូរសុំច្បាប់ពីក្រុមហ៊ុនឬសមាគមជាមុនសិន។
នេះជាច្បាប់ដើម្បីឲ្យអ្នកទាំងអស់គ្នានៅប្រទេសជប៉ុនដោយសុវត្ថិភាពតែប៉ុណ្ណោះ ! ដូចនេះហើយអ្នកត្រូវគោរពវិន័យ ហើយកុំសប្បាយមួយពេលដែលធ្វើឲ្យអ្នកខូចអនាគត !

## ការលួចទំនិញតាមហាង និងជិះកង់ដែលគេទុកចោលទាំងនេះគឺជាអំពើខុសច្បាប់ ដែលមិនអាចលើកលែងបាន !

ជាអកុសលមានការកើនឡើងចំនួនករណីឧក្រិដ្ឋកម្មដែលបង្ករដោយកម្មសិក្សាការីអ្នកហាត់ការជនបរទេសជាដើម !
មិនត្រូវជឿពាក្យលួងលោមគេទេបើទោះបីជាជនជាតិដូចគ្នាក៍ដោយ។ពាក្យផ្អែមល្ហែមគឺជាអន្ទាក់។សូមជឿជាក់លើខ្លួនឯង !

មិនត្រូវឲ្យលិខិតឆ្លងដែននិងប័ណ្ណស្នាក់ទៅកាន់នរណាម្នាក់ក្រៅពីសមាគម ឬក្រុមហ៊ុនទេ !

អ្នកនឹងមិនតម្រូវឲ្យស្នើរដោយផ្ទាល់ខ្លួនទៅខាងអន្តោប្រវេសន៍នោះទេ។ជនខិលខូនតែងតែចង់បានលិខិតឆ្លងដែន ឬប័ណ្ណស្នាក់នៅរបស់អ្នក!

សូមប្រុងប្រយ័ត្ន!